# ដំណាំម្រេច



ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម

*Loan 2022-CAM{SF}*

២០០៨

# ដំណាំម្រេច



ដំណាំម្រេច ជាដំណាំដុះលូតលាស់យូរអង្វែង មានលក្ខណៈជារុក្ខជាតិវល្លិនៅក្នុងតំបន់ត្រូពិចក្ដៅហើយ ដែលមានកម្ពស់ទឹកភ្លៀងប្រចាំឆ្នាំពី ២០០០-២៥០០ មីលីម៉ែត្រ ឬច្រើនជាងនេះ ។ នៅកម្ពុជា ដំណាំម្រេច ជាដំណាំកសិ-ឧស្សាហកម្មសំខាន់សម្រាប់បង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងសេដ្ឋកិច្ចជាតិ ។

ដំណាំម្រេចបានចាប់ផ្ដើមដាំនៅកម្ពុជា តាំងពីសតវត្សន៏ទី ១៩ គឺក្នុងឆ្នាំ ១៨៤០ ដែលមានប្រភពមកពីខេត្តហាយណាន់ ប្រទេសចិន ។ នៅកម្ពុជា ម្រេចគឺជាគ្រឿងទេសមួយសំខាន់ មនុស្សយើងបរិភោគជាអាហារ និងប្រើជាវត្ថុធាតុដើមសម្រាប់ធ្វើឱសថព្យាបាលជម្ងឺ ធ្វើគ្រឿងក្រអូប និងធ្វើថ្នាំកំចាត់សត្វល្អិត ដូចជាសត្វដែលរស់នៅលើសំភារៈធ្វើពីរោមសត្វ និងខ្មៀន ។ ដោយនៅក្នុងផ្លែមានសារជាតិ អាល់កាឡូអ៊ីត ដែលរួមមាន ពីប៉េរីន ពីប៉េរ៉េទីន សាវីរីន គូម៉ាប៉េរីន គីមហ្វេរ៉ូល ហ្គេសេទីន អាស៊ីតកាហ្វេអ៊ីច ហ្គីនីនស៊ីន ពីប៉េរ៉ាមីន ឌីអ៊ីដ្រូពីពែរស៊ីដ បេតា-ស៊ីតូស្តេរ៉ូល និងសារធាតុប្រេង ដែលមានទែរប៉ែន ហ្វេលង់ដ្រែន ការីអូហ្វីឡែន និង

អ៊ុកសីដការីអូហ៊្វីឡែនជាដើម ។

ដំណាំម្រេចជាដំណាំបន្តពូជ និងពង្រីកដោយមើម ដោយកាត់ថ្នាំងផ្នែកខាងលើនៃដើម ដែលមានអាយុចាប់ពីដប់ប្រាំបីខែឡើង ។





## ១-ស្ថានភាពដំណាំម្រេច

### អំពីតំបន់ដាំដុះ :

នៅកម្ពុជា ដំណាំម្រេចត្រូវបានដាំដុះនៅតំបនខ្ពង់រាប និងតំបន់មាត់សមុទ្រ លើប្រភេទដីស្រស់ទឹកល្អ ដូចជានៅក្នុងខេត្តកំពត ក្រុងព្រះសីហនុ ខេត្តកោះកុង ខេត្តកំពង់ចាម មណ្ឌលគិរី និងខេត្តតាកែវ ។ មុនឆ្នាំ ១៩៧០ ផ្ទៃដីដីដាំដុះមានប្រមាណ ៨៦០ ហិកតា និងមានបរិមាណផលសរុបចំនួន ២,៥២០ តោន នៅខេត្តកំពត កោះកុង ក្រុងព្រះសីហនុ និងខេត្តកំពង់ចាម ។



បច្ចុប្បន្ននេះ តំបន់ដាំម្រេចបានពង្រីកទៅខេត្តមួយចំនួន ដូចជាខេត្តមណ្ឌលគិរី និងខេត្តតាកែវជាដើមដែលមានផ្ទៃដីសរុបប្រមាណជាង ១000 ហិកតា ។ លទ្ធភាពដីអាចពង្រីកដល់ជាង ៤000 ហិកតា បើមានទីផ្សារល្អ ។

**អំពីពូជ :**

ដំណាំម្រេចដែលបានធ្វើការដាំដុះនៅកម្ពុជា មានពូជពីរប្រភេទគឺពូជឡាំពុង (LAMPONG) មានប្រភពមកពីប្រទេសឥណ្ឌូនេស៊ី ដែលមានស្លឹកធំ ថ្នាំងវែង កួរវែង និងផ្លែតូច ។ និងពូជកំចាយ (KAMCHAY)មានប្រភពដើមមិនច្បាស់លាស់ហើយមានស្លឹកតូច ថ្នាំងខ្លី និងផ្លែធំ ។





## ២_បរិស្ថានដាំដុះដំណាំម្រេច

ដំណាំម្រេចជាដំណាំប្រភេទត្រូវការដីមានជីជាតិល្អ ជាដីមានជាតិជូរបន្តិច គឺមានកំរិតប៉េហាស pH ពី៥.៥-៧ ហើយសំបូរទៅដោយសារធាតុអាសូតពី ១-១,៥ ភាគរយ ។ ដំណាំម្រេចត្រូវការដីមានស្រទាប់ជ្រៅ ហើយជ្រាបទឹកបានល្អ សំបូរទៅដោយជីធម្មជាតិ ពិសេសដីមមោក និងធាតុរ៉ែ។ ម្រេចត្រូវការប្រភេទដីឥដ្ឋល្បាយខ្សាច់ ឬដីខ្សាច់ល្បាយឥដ្ឋ និងដីក្រហមបាសាល់ ។







ដំណាំម្រេចអាចដុះនៅតំបន់ដែលមានសីតុណ្ហភាព ២៣- ២៨ អង្សាសេ និងកំរិតសំណើមបរិយាកាសពី ៨១-៨២ ភាគរយ បង្កភាពងាយស្រួលសំរាប់លំអងផ្កាឈ្មោល ទៅប៉ះនិងផ្កាញី និងអំណោយផលល្អដល់ការលូតលាស់នៃផ្កាម្រេច។ ម្រេចត្រូវការទឹកភ្លៀងពី ២០០០-៣០០០ មីលីម៉ែត្រក្នុង១ឆ្នាំជាទៀងទាត់ក្នុងរយៈពេលពី ៧-៨ ខែ ក្នុង១ឆ្នាំ ព្រោះរយៈពេលនេះម្រេចត្រូវទុំ ។ កំរិតទឹកតិចបំផុតមិនត្រូវឱ្យតិចជាង ១,៨០០ មីលីម៉ែត្រ ម្រេចត្រូវការភាពស្ងួត និងស្រស់ទឹកក្នុងរយៈពេលពី ៤-៥ ខែ ក្នុង ១ ឆ្នាំ ព្រោះរយៈពេលនេះម្រេចត្រូវការទុំច្រើន

ហើយស្រុះគ្នាទៀតផង ។ ដីណាំម្រេចដុះលូតលាស់ល្អនៅក្នុងរយៈកម្ពស់ពី៨៥០-១០០០ ម៉ែត្រ ធៀបទៅ និង កម្ពស់ទឹកសមុទ្រ ។



## ៣_បច្ចេកទេសដាំដុះម្រេច

### ការរៀបចំដី :



ដីត្រូវភ្ជួររាស់ឱ្យបានជ្រៅគឺពី ៣០-៤០ ស.ម និងឱ្យបានពី ២-៣ សារ ហើយរាស់បំបែកដីឱ្យបានម៉ត់ល្អ ព្រមទាំងប្រមូលស្មៅ កំទេចកំទីចេញឱ្យអស់ពីចំការដើម្បីងាយស្រួលក្នុងការដាំម្រេច និងជៀសផុតពីការបំផ្លាញពីពពួកសត្វល្អិត



និងជម្ងឺផ្សិតផ្សេងៗ

-រាស់ពង្រាបដីឱ្យបានស្មើល្អ ដើម្បីផ្តល់លទ្ធភាពដុះលូតលាស់របស់ដំណាំម្រេច និងងាយស្រួលបញ្ចូលទឹកស្រោចស្រពនៅរដូវប្រាំង និងបើកសំរស់ទឹកនៅរដូវភ្លៀងធ្លាក់ជោគជាំ ។

- លើកពូនរងកម្ពស់ពី ១៥-២០ សង់ទីម៉ែត្រ និងមានទំហំពី ១-១,២ ម៉ែត្រ ដើម្បីទុកសម្រាប់ដាំ និងកាប់កូនឈើដោតលើរង ចង្វាយពីមួយទៅមួយ ២ ម៉ែត្រទុកសម្រាប់កាប់រណ្តៅដីឱ្យបានត្រង់ល្អ ។

**ការជ្រើសរើសពូជ :**



ម្រេចដែលយើងយកមកដាំត្រូវមានអាយុយ៉ាងតិច ១ ឆ្នាំហើយមានឫសខ្ចីគ្រប់ថ្នាំងទាំងអស់ និងមានមែកគ្រប់ថ្នាំង ហើយគ្មានកើតជម្ងឺ មានទងប្រវែងពី ៤០-៥០ ស.ម



មានថ្នាំងញឹក ចន្លោះថ្នាំងនីមួយៗមានប្រវែង ១០ សង់ទីម៉ែត្រ ។ ទងដែលកាត់ចេញពីចំការត្រូវយកទៅដាំ មិនត្រូវទុកឱ្យលើសពី ២-៣ ម៉ោងឡើយ ។

**របៀបដាំ :**

ជាទូទៅការដាំម្រេចដែលទទួលបានលទ្ធផលល្អ ត្រូវអនុវត្តដាំចាប់តាំងពីខែ កក្កដា-សីហា ហើយមុនដាំត្រូវត្រាំទងក្នុងទឹករយៈពេលពី ១-២ ម៉ោង ដើម្បីឱ្យទងមានលទ្ធភាពដុះឫសថ្មីៗបានល្អ ។ ត្រូវជីករណ្តៅលើខ្នងរងមានទំហំ 0,៤ x 0,៤ x 0,៥ ម៉ែត្រ។ ដាំ ២ ទងក្នុង ១ រណ្តៅ ដោយកប់ក្នុងជម្រៅ ២ ថ្នាំងទៅក្នុងដី និងចម្ងាយពីគុម្ពមួយទៅគុម្ពមួយមានចម្ងាយ ២ ម៉ែត្រ ។ ត្រូវដាំចំនួន ២,៥០០ ជន្លង់ក្នុងដី ១ ហិកតា ពេលដាំរួចភ្លាមត្រូវគ្របស្លឹកឈើ ដើម្បីការពារកំដៅថ្ងៃនៅកន្លែងដាំ ។ បន្ទាប់ពីដាំបានរយៈពេលពី ៣-៤ ខែ និងជាពេលដែលយើងសង្កេតឃើញថាដំណាំម្រេចមានការដុះលូត





លាស់ល្អ ត្រូវដាក់ជន្លង់ឈើខ្លឹម ដែលមានអង្កត់ផ្ចិតទំហំ ១០ ទៅ ១,២ សង់ទីម៉ែត្រ នៅគ្រប់រណ្ដៅនីមួយៗដែលមានចំនួន ២,៥០០ ជន្លង់ក្នុង ១ ហិកតា ។ ឈើធ្វើជន្លង់ត្រូវជ្រើសរើសឈើខ្លឹមមាំ មានអាយុកាលវែង ដូចជាឈើជាដើម ដើម្បីជៀសវាងការផ្លាស់ប្ដូរជន្លង់នៅក្នុងដំណាក់កាលកំពុងលូតលាស់របស់ដំណាំម្រេច ។

**របៀបថែទាំ :**

ត្រូវជំរះស្មៅធ្វើឱ្យបានច្រើនសារពេលឃើញមានស្មៅដុះច្រើន ដែលជា





ហេតុធ្វើឱ្យកូនម្រេចអន់ ការជំរះស្មៅត្រូវធ្វើឱ្យបានពី ២-៣ សារក្នុងរដូវប្រាំង និងពី ៤-៥ សារក្នុងរដូវវស្សា ។ ត្រូវចាក់បន្ថែមដីឆៅ ឬដីថ្មីពី ៣-៤ អំរែកក្នុង១គុម្ពឱ្យបាន ២ ដងក្នុង ១ ឆ្នាំ នៅដើម និងចុងរដូវភ្លៀង ដើម្បីបង្កើនជីជាតិដី និងការលូតលាស់ឫសផ្នែកខាងលើនៃដើមម្រេច ។



## ៤. ការកាត់តែងដំណាំម្រេច

ការកាត់តែងដំណាំម្រេចសំខាន់ណាស់ ដូចជាការចងទង និងបេះផ្កាចោល ធ្វើឱ្យម្រេចបែកគុម្ព និងដុះលូតលាស់ឡើងជន្លង់បានល្អ ។

នៅកម្ពុជា ការស្រោចទឹកគឺចាប់ផ្ដើមនៅចុងរដូវភ្លៀងពីខែវិច្ឆិការហូតដល់ដើមរដូវភ្លៀងវិញ



ក្នុងខែមេសា ធ្វើក្នុងអំឡុង ១០-១៥ ថ្ងៃម្តងដោយបូមទឹកស្រោចតាមចន្លោះរង បរិមាណទឹកដែលត្រូវបូមស្រោចគឺពី ២០០-៣០០ ម៉ែត្រគូប ក្នុង១ហិកតា និងប្រើប៉ោតដងទឹកស្រោចតាមគល់បន្ថែមដោយស្រោចពី ២-៣ ថ្ងៃម្តង ។

ការកាប់ជ្រួយបន្ធូរដី ត្រូវធ្វើនៅតាមបណ្តោយរងដោយធ្វើ ២-៣ ដងក្នុង ១ ឆ្នាំ នៅចុង និងដើមរដូវភ្លៀង ដើម្បីរក្សាសំណើមទឹកក្នុងដី និងដីធូហើយធ្វើឱ្យឫសម្រេចស្រូបទឹក និងជីជាតិមានជាប្រចាំនៅក្នុងដី ។

## ៥. ការប្រមូលផល



ដំណាំម្រេចផ្តល់ផលចាប់ពីឆ្នាំទី ៣ ហើយទិន្នផលមានការប្រែប្រួលទៅតាមអាយុកាលរបស់វា ដែលក្នុងរយៈពេលចាប់ពីអាយុ ៣-៨ ឆ្នាំ ម្រេចផ្តល់ទិន្នផល



មធ្យមពី ៤-១០ គីឡូក្រាម ម្រេចស្រស់ក្នុង ១ ជន្លង់ ឬ ១០ តោនទៅ ២០ តោនគ្រាប់ម្រេចក្នុង ១ ហិកតា ឬ ផលិតផលគ្រាប់ម្រេចស្ងួតពី ២-៤ តោន ក្នុង ១ ហ.ត ចាប់ពីអាយុ ១២-១៥ ឆ្នាំឡើងទៅ ទិន្នផលថយចុះជាមធ្យមនៅត្រឹម ២-២.៥០ គីឡូក្រាមគ្រាប់ម្រេចស្រស់ក្នុង ១ ជន្លង់ ។ យើងបេះគ្រាប់ទុំពេញលេញ ហាលសម្ងួតដោយកំដៅថ្ងៃ ឬប្រើឡសម្ងួត ។

គ្រាប់ម្រេចគឺជាផលិតផលគ្រឿងទេសដ៏សំខាន់ និងមានតម្លៃដោយយើងប្រើប្រាស់វាជាម្ហូបអាហារ និងជាថ្នាំព្យាបាលជម្ងឺ និងកំចាត់សត្វល្អិតបំផ្លាញ ។ ដូច្នេះនៅកម្ពុជាដំណាំម្រេច ជាដំណាំកសិ-ឧស្សាហកម្មដ៏សំខាន់សម្រាប់បង្កើនប្រាក់ចំណូលក្នុងគ្រួសារ និងសេដ្ឋកិច្ច ។



ការផ្សាយរបស់ក្រុមការងារផ្សព្វផ្សាយ

បច្ចេកវិទ្យាកសិកម្ម